# សេចក្តីប្រកាសរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ក្នុងឋានៈជាអតីត អគ្គលេខាធិការនៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រ.ជ.រ.ប.ខ) និងជាអតីត សមាជិកក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (អេស អិន ស៊ី) ទាក់ទងនឹងអតីតជំរុំជនភៀសខ្លួនខ្មែរ

នៅឆ្នាំ១៩៨២ ខ្ញុំបានចាកចេញពីប្រទេសបារាំងមកចូលរួមជាមួយរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ(រ.ជ.រ.ប.ខ.) ដែលបោះជំរុំនៅលើទឹកដីខ្មែរជាប់ព្រំដែនប្រទេសថៃ មានជំរុំនងចាន់ (សម័យឥឡូវហៅថា ភូមិជោគជ័យ នៅក្បែរភូមិថៃឈ្មោះបានណងចាន់) ជំរុំរិទ្ធិសែន (នៅក្បែរភូមិថៃឈ្មោះបានណងសាម៉េត) ជំរុំអំពិល (នៅក្បែរភូមិថៃឈ្មោះបានសាង៉ែ)។ នៅជាប់ជំរុំអំពិល មានជំរុំមួយទៀតឈ្មោះជំរុំសម្លូឆ្ងាញ់នៅលើទឹកដីខ្មែរ និងនៅខេត្តឆ្ងាយៗពីនោះ មានជំរុំអូរបុក ជំរុំណាំយឺន និងជំរុំសុខសាន្ត។ មកពីប្រទេសបារាំងភ្លាម ខ្ញុំបានមកស្នាក់មួយយប់នៅជំរុំនងចាន់ ដែលនៅពេលនោះមានលោក ជា រិទ្ធីឈុត ជាប្រធាន លោក ស៊ូ គឹមស៊ុន ជាអនុប្រធាន និងលោក ជុំ ឈាង ជាប្រធានរដ្ឋបាលមុនពេលគាត់ចេញទៅធ្វើជាប្រធានជំរុំដងរែក ដែលត្រូវបំបែកចេញពីជំរុំនងចាន់។ ជំរុំទាំងអស់សុទ្ធតែតាំងនៅលើទឹកដីខ្មែរទាំងអស់។ ប្រជាពលរដ្ឋស៊ីវិលបោះទីតាំងស្នាក់នៅជាប់ព្រំប្រទល់ ឯកងប្រដាប់អាវុធរស់នៅដោយឡែក និងដាក់ខ្សែត្រៀមជ្រៅនៅក្នុងទឹកដីខ្មែរ។ ក្រោយជំរុំនងចាន់ត្រូវបាក់បែក ប្រជាពលរដ្ឋស៊ីវិលនៃជំរុំនេះបានត្រូវបញ្ជូនឱ្យទៅបោះជំរុំនៅព្រៃចាន់ដែលជាប់នឹងជំរុំរិទ្ធិសែន។

នៅទសវត្សរ៍ ១៩៨០ ជំរុំទាំងអស់ត្រូវទទួលរងការវាយប្រហារជាញឹកញាប់ពីសំណាក់កងទ័ពរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយមានជំនួយពីកងទ័ពវៀតណាមផង។ នៅពេលវាយប្រហារនោះគ្មានកងទ័ព ឬ កងកម្លាំងថៃណាមួយចេញមកប្រយុទ្ធការពារជំរុំទាំងអស់នោះទេ ព្រោះជាជំរុំខ្មែរស្ថិតនៅលើទឹកដីខ្មែរ។ ដូច្នេះថៃមិនអាចអះអាងថា ថៃបានបើកទទួលជនជាតិខ្មែរឱ្យបោះជំរុំទាំងអស់នោះរស់នៅលើទឹកដីថៃ ដូចអ្វីដែលរដ្ឋមន្ត្រីការបរទេសថៃ លោក Sihasak Phuangketkeow និយាយប្រាប់កាសែតអន្តរជាតិនោះទេ។ ឆ្នាំ១៩៨៤-១៩៨៥ ជំរុំទាំងអស់នោះត្រូវបានបោសសម្អាត រីឯប្រជាពលរដ្ឋដែលជាជនជម្លៀសខ្លួន ក៏ត្រូវបានអនុញ្ញាតឱ្យទៅរស់នៅក្នុងជំរុំលើទឹកដីថៃ ដូចជាជំរុំសាយធូ សម្រាប់ភាគី រ.ជ.រ.ប.ខ ជំរុំសាយប៊ី សម្រាប់ភាគីសម្តេចព្រះនរោត្តម សីហនុ និងជំរុំឯទៀតសម្រាប់ភាគីខ្មែរក្រហម។ សូមបញ្ជាក់ថា នៅសម័យនោះជនភៀសខ្លួនខ្មែរបែកចេញជាពីរប្រភេទគឺ៖ ប្រភេទទី១ ជនភៀសខ្លួនពេញសិទ្ធិ (Refugee) មានសិទ្ធិចេញទៅរស់នៅប្រទេសទី៣ ប្រភេទទី២

ជាជនជម្លៀសខ្លួន (Displaced person) ជាក្រុមដែលត្រូវត្រៀមធ្វើមាតុភូមិនិវត្តន៍។ ជនភៀសខ្លួនប្រភេទទី១ ថៃអនុញ្ញាតឱ្យចូលទៅរស់នៅក្នុងជំរុំលើទឹកដីថៃ ដូចជាជំរុំ ខៅ-អី-ដាង ជាដើម។ ជនភៀសខ្លួនប្រភេទទី២ ជាជនភៀសខ្លួនមិនពេញសិទ្ធិ ឬជនជម្លៀសខ្លួន( Displaced person )ដែល ស្នាក់ក្នុងជំរុំរបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងជំរុំភាគីអ្នកតស៊ូឯទៀត គ្មានសិទ្ធិចូលទៅក្នុងទឹកដីថៃទេ បើចូលទៅក្នុងទឹកដីថៃជនជម្លៀសខ្លួនខ្មែរទាំងនោះនឹងត្រូវតម្រួតថៃចាប់ដាក់គុកនិងធ្វើបាប។ ជនភៀសខ្លួនទី១ ស្ថិតនៅក្រោម ការការពារ និងឧបត្ថម្ភរបស់ឧត្តមស្នងការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន (UNHCR) ចំណែកជនភៀសខ្លួនប្រភេទទី២ ឬជនជម្លៀសខ្លួន បានទទួលការឧបត្ថម្ភពីអង្គការដែលមានឈ្មោះថា ប្រតិបត្តិការសង្គ្រោះព្រំដែនអង្គការសហប្រជាជាតិ ឬយូអិនប្រូ (UNBRO)។ ជំរុំជនភៀសខ្លួនបានត្រូវបិទជាស្ថាពរ នៅពេលជនភៀសខ្លួនទាំងនោះចេញដំណើរអស់ទៅប្រទេសទី៣។ ចំណែកជំរុំជនជម្លៀសខ្លួនដូចជា ជំរុំសាយធូ សាយប៊ី ជាដើមក៏ត្រូវបិទទាំងស្រុងនៅពេលធ្វើមាតុភូមិនិវត្តន៍ចប់សព្វគ្រប់។

ចាប់តាំងពីពេលដែលកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសបានចូលជាធរមាន ជនជម្លៀសខ្លួនខ្មែរទាំងអស់នោះ ត្រូវបានធ្វើមាតុភូមិនិវត្តន៍អស់គ្មានសល់ម្នាក់ឡើយ។ ដូច្នេះការអះអាងរបស់ភាគីថៃថាជនជាតិខ្មែរខ្លះបន្តរស់នៅលើទឹកដីថៃរាប់សិបឆ្នាំមកហើយ ជាពាក្យភូតភរកុហកទាំងស្រុង។ នៅទសវត្សរ៍១៩៩០ នៅពេលប្រទេសទទួលសន្តិភាព ប្រជាពលរដ្ឋខ្មែរចាប់ផ្ដើមមករស់នៅបណ្ដើរៗ និងជាពិសេសក្រោយឆ្នាំ១៩៩៨ ដោយសារនយោបាយឈ្នះៗរបស់សម្ដេចតេជោ ហ៊ុន សែន ប្រជាពលរដ្ឋខ្មែរចាប់ផ្ដើមសាងសង់ផ្ទះធំ តូច ផ្ទះឈើ ឬផ្ទះថ្ម ព្រមទាំងធ្វើស្រែចំការលើទឹកដីខ្មែរដែលជាអតីតទីតាំងជំរុំចលនាតស៊ូ(អតីតជំរុំនងចាន់ ឬអតីតជំរុំរិទ្ធិសែន ជាដើម)រហូតមក ដោយគ្មានបញ្ហាជាមួយអាជ្ញាធរថៃ និងប្រជាពលរដ្ឋថៃនៅតាមព្រំដែនសោះឡើយ។ លោកអតីតរដ្ឋមន្ត្រីការពារប្រទេសថៃ ប្រាវិត វង្សសុវណ្ណ ធ្លាប់ចេញវីឌីអូបញ្ជាក់អំពី ការចូលមករស់នៅលើទឹកដីអតីតជំរុំរបស់ប្រជាពលរដ្ឋខ្មែរលើទឹកដីខ្មែរជាយូរមកហើយ។ ម្យ៉ាងទៀតការលួចចូលមកក្នុងទឹកដីដែនអធិបតេយ្យភាពខ្មែរ នៅម្ដុំភូមិជោគជ័យ ចន្លោះបង្គោល៤៦ និង៤៧ ដោយអត់ច្បាប់របស់ជនជាតិថៃជាតិនិយមជ្រុលម្នាក់ឈ្មោះ វិរៈ ស៊ុមខ្វាមឃិត កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ដែលត្រូវអាជ្ញាធរខ្មែរបានចាប់ដាក់ពន្ធនាគារ និងដោះលែងនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៤ បានបញ្ជាក់ច្បាស់ថាមានតែអាជ្ញាធរខ្មែរមួយគត់ជាអ្នកគ្រប់គ្រងទឹកដីនៅតំបន់នោះ។

ទាក់ទងនឹងតំបន់បឹងត្រកួន រហូតមកដល់ចុងទសវត្សរ៍ ១៩៨០ តំបន់នេះគ្មានមនុស្សស្នាក់នៅទេ។ ក្រោយជំរុំអំពិលនិងទីតាំងយោធាហៅបន្ទាយអំពិលត្រូវបានបាក់បែកមួយរយៈមក ប្រហែលនៅក្នុងរង្វង់

ឆ្នាំ១៩៨៩ លោកឧត្តមសេនីយ៍ ជៀន ដែល បានដឹកនាំកងកម្លាំងសាងសង់ផ្ទះសម្បែងកើតបានជាភូមិឋានមុនគេ។ បន្ទាប់មកក៏រៀបចំជាបន្ទាយ មានឈ្មោះថាបន្ទាយមានរិទ្ធ នៅលើទឹកដីខ្មែរ។ នៅសម័យអ៊ុនតាក់(UNTAC) ភាគីលោកឧត្តមសេនីយ៍ សក់ ស៊ុតសាខន-ជៀនដែល គ្រប់គ្រងតំបន់បន្ទាយមានរិទ្ធ-បឹងត្រកួន ឯភាគីលោកតា(សម្តេចបវរសេដ្ឋា) សឺន សាន គ្រប់គ្រងតំបន់ថ្មពួក-បន្ទាយឆ្មារ។ ក្រុមអ៊ុនតាក់ដឹងឮរឿងនេះយ៉ាងច្បាស់ ឯសម្តេចព្រះ នរោត្តម សីហនុ ប្រធាន អេស អិន ស៊ី (SNC) នាសម័យនោះ បានយាងទៅបំពេញព្រះទស្សនកិច្ចនៅតំបន់ទាំងពីរគឺ ថ្មពួក-បន្ទាយឆ្មារ និងនៅបន្ទាយមានរិទ្ធ-បឹងត្រកួន ផងដែរ។ នៅពេលនោះ មន្ត្រីថៃទទួលស្គាល់ថាជាទឹកដីខ្មែរពិតប្រាកដ គ្មានការជំទាស់តវ៉ាអ្វីឡើយ។

ក្រោយមក បន្ទាប់ពីការវិលត្រឡប់មករស់នៅក្នុងតំបន់ជំរុំចាស់ទាំងនេះ ប្រជាពលរដ្ឋកម្ពុជាបានបង្កើតភូមិឋាន និងមានការអភិវឌ្ឍជាបន្តបន្ទាប់ ដោយមានការដឹងឮពីអាជ្ញាធរនៃប្រទេសទាំងពីរ។ ប៉ុន្តែចំពោះការកាន់កាប់នៅលើដីជាក់ស្តែងហួសខ្សែព្រំដែនបែបណានោះ មានតែគណៈកម្មការ JBC តែប៉ុណ្ណោះដែលដឹងច្បាស់តាមរយៈឯកសារដែលបន្សល់ទុកពីសម័យបារាំង (ដូចជា សន្ធិសញ្ញា អនុសញ្ញា ផែនទី កំណត់ហេតុបោះបង្គោលព្រំដែនជាដើម)។ ទន្ទឹមនេះ ចាប់ពីឆ្នាំ២០០៦ គណៈកម្មការចម្រុះព្រំដែន កម្ពុជា-ថៃ (JBC) បានព្រមព្រៀងគ្នាចុះស្វែងរុករកទីតាំងពិតប្រាកដនៃបង្គោលព្រំដែនដែលបានបោះសម័យបារាំង ហើយបានវាស់វែងនិងផ្ទៀងផ្ទាត់ខ្សែព្រំដែននៅលើដីជាក់ស្តែង ដោយផ្អែកលើមូលដ្ឋាននៃសន្ធិសញ្ញា អនុសញ្ញា ផែនទី កំណត់ហេតុបោះបង្គោលព្រំដែន ដែលបន្សល់ទុកពីសម័យបារាំង។

ការបន្តកាន់កាប់ទឹកដីខ្មែរដោយកងទ័ពថៃ ជាការរំលោភបំពានអធិបតេយ្យភាពរបស់កម្ពុជាយ៉ាងជាក់ច្បាស់ និងបញ្ជាក់ថាមេដឹកនាំថៃបង្កសង្គ្រាមជាមួយកម្ពុជា ដើម្បីទន្ទ្រានយកទឹកដីកម្ពុជាតែប៉ុណ្ណោះ មិនមែនដោយសារដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើឆបោកអនឡាញ ឬក្រោមរូបភាពប្រយុទ្ធប្រឆាំងការដាក់មីនថ្មីរជើងនោះឡើយ។ ម្យ៉ាងទៀតសង្គ្រាមឈ្លានពានកម្ពុជា ក៏ជាផលប្រយោជន៍ដែលគណបក្សនយោបាយថៃទាញយក តាមស្មារតីជាតិនិយមជ្រុលសម្រាប់យុទ្ធនាការប្រកួតប្រជែងតំណែងនាយករដ្ឋមន្ត្រីក្នុងការបោះឆ្នោតកន្លងទៅថ្មីៗនេះ។

បើភាគីថៃពិតជាចង់រកដំណោះស្រាយទ្វេភាគីដោយសន្តិវិធីពិតប្រាកដមែន ភាគីថៃត្រូវតែបញ្ឈប់ជាបន្ទាន់នូវសកម្មភាពកែប្រែទីតាំងព្រំប្រទល់ និងត្រូវតែអនុញ្ញាតឱ្យក្រុមការងារវាស់វែងចម្រុះនៃប្រទេសទាំងពីរ (Joint Survey Team) ធ្វើការវាស់វែងជាបន្ទាន់ មិនចាំបាច់រង់ចាំឱ្យមានការបង្កើត ៥

រដ្ឋាភិបាលថ្មីនោះឡើយ។ ព្រោះនៅពេលភាគីថៃប្រាប់ភាគីខ្មែរឱ្យរង់ចាំការបង្កើតរដ្ឋាភិបាលថៃថ្មី ទាហានថៃគិតតែពីបំពានលើបទឈប់បាញ់ និងបន្តសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដាក់កុងទើន័រ រាយលួសបន្លាព័ទ្ធយកទឹកដីខ្មែរ ឥតរង់ចាំរដ្ឋាភិបាលថ្មីនេះទេ។

ខ្ញុំសូមប្រកាសគាំទ្រទាំងស្រុងនូវវិធានការដោះស្រាយទំនាស់របស់ សម្តេចធិបតីនាយករដ្ឋមន្ត្រី ដែលបានលើកឡើងក្នុងបទសម្ភាសន៍ជាមួយ Reuters និង Fox news នៅសហរដ្ឋអាមេរិក។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦

- ទូរស័ព្ទទំនាក់ទំនង : ០១២ ៦៥៦ ០១៣
- Website : www.ieng mouly.net